# សកលវិទ្យាល័យ អាតេណេអូ ម៉េនីឡា (ATENEO DE MANILA)

## សាលារដ្ឋ

## អភិបាលកិច្ចល្អ, ការទទួលខុសត្រូវសង្គម និងវិមជ្ឈការ

## ១. អភិបាលកិច្ចល្អ

យើងប្រកាន់ភ្ជាប់នូវឧត្តមគតិពិតប្រាកដនៅទូទាំងសកលលោក ដែលនាំអោយយើងធ្វើអ្វីដែលល្អ វាមិនគ្រាន់តែដើម្បីយើងប៉ុណ្ណោះទេ គឺដើម្បីសង្គមទាំងមូល។ ឧត្តមគតិទាំងនេះបង្ហាញផ្លូវ និងដឹកនាំយើងអោយចេះទាមទារនូវតំរូវការពីអ្នកដឹកនាំរបស់យើង ក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តប្រកបដោយភាពសុច្ចរិត និងក្តីស្មោះត្រង់ ព្រមទាំងបញ្ជាក់ថាតើសេចក្តីសំរេចមួយណាដែលបានអនុវត្តន៍ហើយ និងមួយណាមិនបានអនុវត្តន៍។ វាធ្វើអោយយើងធ្វើការដើម្បី ទាមទារនូវអភិបាលកិច្ចល្អ។

***ប៉ុន្តែតើអ្វីជាអភិបាលកិច្ច? និងតើអ្វីជាអភិបាលកិច្ចល្អ?***

"អភិបាលកិច្ច " គឺជាការប្រើនូវឥទ្ធិពល ឬអំណាច- នយោបាយ សេដ្ឋកិច្ច រដ្ឋបាល ឬអ្វីផ្សេងៗដើម្បីគ្រប់គ្រងកិច្ចការ និងធនធានរបស់ប្រទេសមួយ។ វារួមបញ្ចូលទាំងដំណើការ និងគ្រឹះស្ថានយន្តសម័យ តាមរយៈប្រជាពលរដ្ឋ និងក្រុមនានា ដែលបង្ហាញនូវចំណាប់អារម្មណ៏របស់ពួកគេ, ប្រើប្រាស់នូវសិទ្ធស្របច្បាប់របស់គេ, សំរេចបាននូវកតព្វកិច្ចរបស់គេ និងសម្រុះសម្រួលភាពខុសប្លែកគ្នារបស់គេ។"អភិបាលកិច្ចល្អ" មានន័យថាការគ្រប់គ្រងកិច្ចការ និងធនធានរបស់ប្រទេសជាតិប្រកបដោយសមត្ថភាព និងមានលក្ខណៈបើកទូលាយ, តម្លាភាព, ការទទួលខុសត្រូវ, សមភាព និងឆ្លើយតបនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ [១]

***អភិបាលកិច្ចល្អ គឺអាស្រ័យលើគោលការណ៍ខាងក្រោម:*** [២]

ក. អភិបាលកិច្ចល្អ គឺផ្តោតលើគោលបំណង និងឥទ្ធិពលរបស់គំរោងចំពោះប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវា។

ខ. អភិបាលកិច្ចល្អ គឺជាការអនុវត្តយ៉ាងមានប្រសិទ្ធិភាព ដោយកំណត់នូវមុខងារ និងតួនាទីយ៉ាងច្បាស់លាស់។

គ. អភិបាលកិច្ចល្អ គឺជាការផ្សព្វផ្សាយនូវគុណតម្លៃរបស់អង្គភាពទាំងមូល ហើយព្រមទាំងបង្ហាញគុណតម្លៃនានារបស់អភិបាលកិច្ចល្អ តាមរយៈឥរិយាបថ។

ឃ. អភិបាលកិច្ចល្អ គឺជាការផ្តល់នូវការជូនដំណឹង, ការសំរេចចិត្តប្រកបដោយតម្លាភាព, និងការគ្រប់គ្រងហានិភ័យ។

ង. អភិបាលកិច្ចល្អ គឺជាការបង្កើននូវសមត្ថភាព និងភាព អង់អាចក្នុងការដឹកនាំខ្លួន អោយមានប្រសិទ្ធភាព។

ច. អភិបាលកិច្ចល្អ គឺជាការ ជម្រុញអ្នកពាក់ពន្ធ័នានា មិងធ្វើអោយការទទួលខុសត្រូវក្លាយ ជាការពិត។

***អភិបាលកិច្ចល្អ...***

- ជាប្រសិទ្ធភាព និងសមភាព
- ផ្សព្វផ្សាយក្បួនច្បាប់
- បង្ហាញថា នយោបាយ, សេដ្ឋកិច្ចសង្គម ជាអទិភាព គឺអាស្រ័យលើ មតិទូទៅធំមួយក្នុងសង្គម។
- បង្ហាញថាអ្នកក្របំផុត និងអ្នក ដែលងាយរងគ្រោះក្នុងសង្គមដឹងឮ ពីការធ្វើសេចក្តី សំរេចចិត្ត ក្នុងការបែងចែកធនធានអភិវឌ្ឍន៏នានា។

គោលការណ៏រទាំងនេះបើសិនជាបានយកទៅប្រើនៅ ក្នុងវិធីសាស្ត្រដែលរដ្ឋាភិបានអនុវត្តន៏នូវសេចក្តី សំរេចចិត្តនានា នោះនឹងបង្ហាញពីចរិកលក្ខណះដូចខាងក្រោមះ

### ***ក. ការចំលរួម***

រដ្ឋាភិបាលជាកន្លែងដែលអភិបាលកិច្ចល្អតាំងនៅ ប្រជាជនអាចចូលរួមក្នុងការធ្វើការសេចក្តីសំរេចចិត្តយ៉ាងសកម្ម ដោយផ្ទាល់ ឬ ដោយប្រយោល តាមរយះក្រុម ឬ ភ្នាក់ងារ ដែលបង្ហាញពីចំណាប់អារម្មណ៏របស់គាត់។

### ***ខ. ក្បួនច្បាប់***

អភិបាលកិច្ចល្អ អាចធ្វើអោយច្បាប់, សិទ្ធិមនុស្សជាពិសេស, អនុវត្តន៏បានប្រកបដោយយុត្តិធមិ និងមិនលំអៀង។

### ***ឃ. តម្លាភាព***

តម្លាភាពគឺជាការកសាងចរន្តពតិមានដោយសេរី។ ដំណើរការ, ស្ថាបន័ និងពតិមាននានា ដោយទទួលយកនូវការព្រួយបារម្ភដោយផ្ទាល់ទាំងនោះជាមួយពួកគេ និងផ្តល់ពតិមានគ្រប់គ្រាន់ ដើម្បីស្វែងយល់ និងត្រួតពិនិត្យពួកគេ។

### ***ង. មានការទទួលខុសត្រូវ***

នៅក្នុងការអនុវត្តន៏នូវអភិបាលកិច្ចរបស់រដ្ឋាភិបាល បណ្តារភ្នាក់ងារផ្តល់សេវាឆាប់រហ័យ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការសំខាន់ៗរបស់វា។

### ច. ការបង្ហាញមតិទូទៅ

ចំណាប់អារម្មណ៏ និងមតិយោបល់មានភាពខុសគ្នា គ្រប់សង្គមទាំងអស់។ អភិបាលកិច្ចល្អខិតខំយ៉ាងខ្លាំង ដើម្បីសម្រុះសម្រួលភាពខុសគ្នាទាំងនេះ អោយក្លាយជាមតិទូទៅរួមមួយ ចំពោះអ្វីដែលល្អបំផុត ដើម្បីសសំរេចរាល់កិច្ចការទាំងអស់។

### ឆ. សមធមិ

គ្រប់បុរស និងស្ត្រី, មិនប្រកាន់អាយុ, យេនឌ័រ ឬ ស្ថានភាព នៅក្នុងជីវិតរស់នៅសុទ្ធតែមានឱកាស ដើម្បីពង្រីក ឬ ការពារនូវទង្វើល្អរបស់គេ។

### ជ. ប្រសិទ្ធភាព និងប្រសិទ្ធផល

រដ្ឋាភិបាលអនុវត្តន៏នូវអភិបាលកិច្ចល្អ ដើម្បីផលិតនូវសមទ្ធិផលដែលសមស្របនិងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់ធនធានអោយបានប្រសើរ។

### ឈ. ការទទួលខុសត្រូវ

ក្នុងវិស័យអភិបាលកិច្ចល្អរដ្ឋាភិបាលជាអ្នកធ្វើសេចក្តីសំរេចចិត្ត, វិស័យឯកជន និងអង្គការសង្គមស៊ីវិលគឺឆ្លើយតបទៅដល់សារធារណៈជន ពោលគឺស្ថាប័នពាក់ពន្ធ័នានា។

### ញ. ទស្សនៈវិស័យជាយុទ្ធសាស្ត្រ

បណ្តារអ្នកដឹកនាំ និងសាធារណៈជនត្រូវមានទស្សនៈរយៈពេលវែងរួមគ្នាមួយ លើវិស័យអភិបាលកិច្ចល្អ និងការអភិវឌ្ឍន៏មនុស្ស ដោយផ្សារភ្ជាប់ទៅនិងសេចក្តីត្រូវការដើម្បីការអភិវឌ្ឍ។

អភិបាលកិច្ចល្អជាឧត្តមគតិមួយដែលលំបាកក្នុងការអនុវត្ត និងជាពិសេសជាងនេះទៅទៀតគឺជាទាមទារ ហើយជាពិសេសក្នុងសង្គដែលមានគុណតម្លៃថ្លៃថ្នូរ អនុវត្តន៏នូវគោលនយោបាយមិនយុត្តិធមិ និងមានអំពើពុករលួយ។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋ បានចំណាយពេលយ៉ាងច្រើនក្នុងការឃ្លាំមើលកំហុសឆ្គងរបស់អភិបាលកិច្ចល្អ ដូចជាគុណតម្លៃដែលបានផ្សារភ្ជាប់ជាកំហិតចំពោះមន្ត្រីសាធារណៈ។ ចំពោះអភិបាលកិច្ចល្អពិតប្រាកដ ប្រជាជនគួរតែដឹងថា វាមិនមែនជាការអនុវត្តផ្តាច់មុខចំពោះរដ្ឋាភិបាលនោះទេ។

ការធ្វើអោយមានអភិបាលកិច្ចល្អ គឺមានសារៈសំខាន់ទោះបីជាមានការលំបាកក៏ដោយ ប៉ុន្តែត្រូវតែធ្វើ។ រដ្ឋាភិបាលដែលមានទទួលខុសត្រូវ គឺជាការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រយ៉ាងសំខាន់។ ពួគគេការពារសិទ្ធិមនុស្ស ផ្តល់សន្តិសុខ លើកស្ទួយសេដ្ឋកិច្ចអោយរីកចំរើន និងជាអ្នកផ្តល់សេវាយ៉ាងសំខាន់ ដូចជាវិស័យសុខាភិបាល និងអប់រំ។ អភិបាលកិច្ចល្អនាំអោយវិស័យទាំងអស់មានភាពរីកចំរើន និងជឿនលឿន។ វាបង្ហាញពីការអភិវឌ្ឍប្រកបដោយនិរន្តភាព។

ប្រជាពលរដ្ឋជាផ្នែកមួយដ៏ល្អប្រសើរសំរាប់រដ្ឋាភិបាល ពួកគាត់មិនមែនគ្រាន់តែជាអ្នកទទួលផល ឬ អ្នកចូលរួមប៉ុណ្ណោះទេ ពួគគាត់ជាអ្នកបោះឆ្នោត។ វាជាទីក្រុងដែលដាក់ប្រជាជនអោយនៅក្នុងការិយាល័យ និងជាការខិតខំប្រឹងប្រែងរបស់គាត់ ដែលរក្សាពួកគាត់អោយនៅទីនោះ។

## ២. ការទទួលខុសត្រូវសង្គម

តើការទទួលខុត្រូវសង្គមមានន័យដូចម្តេច? វាមានន័យថា ប្រជាពលរដ្ឋធ្វើការរួមគ្នា ដើម្បីធ្វើអោយប្រាកដថា រាជរដ្ឋាភិបាលរបស់គាត់គ្រប់គ្រងធនធានរបស់គេយ៉ាងមានប្រសិទ្ធភាព តម្លាភាព និងសមស្របទៅនិងសេចក្តីត្រូវការរបស់សហគមន៍។ ប្រជាពលរដ្ឋខ្លួនគាត់ និងក្លាយជាគន្លឹះក្នុងការពង្រឹងការទាមទារតំរូវការសេវាកម្មពីរដ្ឋាភិបាល។ ក្នុងវិស័យការទទួលខុសត្រូវសង្គម ប្រជាពលរដ្ឋត្រូវធ្វើអោយប្រាកដថា រដ្ឋាភិបាលរបស់គាត់កំពង់បំរើការដើម្បីពួកគាត់។ វាជួយប្រជាពលរដ្ឋក្នុងការធ្វើអោយប្រាកដថា រដ្ឋាភិបាលកំពង់បំរើការដើម្បី ធ្វើអោយមានាការរីកចំរើន និងជឿនលឿនលើគ្រប់វិស័យ។

ការទទួលខុសត្រូវសង្គម បានកើតចេញពីបំណងប្រាថ្នារបស់ប្រជាជន ដើម្បីការអភិវឌ្ឍមនុស្ស និងមានគោលដៅសំខាន់ៗ ដើម្បីអនុវត្តន៏ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងនិរន្តភាពតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រង។ វាត្រូវការទាំង មន្ត្រីសាធារណៈ នយោជិតឯកជន ឬ អ្នកផ្តល់សេវានានា ដើម្បីឆ្លើយតមទៅនិង គោលនយោបាយ សកម្មភាព និងការប្រើប្រាស់ប្រាស់មូលនិធិរបស់គេ។ វាជាវិធីសាស្ត្រដែលបាន ព្រមព្រៀងដោយសង្គមស៊ីវិល ឬ រដ្ឋ សំដៅកសាងការទទួលខុស និងការឆ្លើយតបរបស់រដ្ឋភិបាល ដោយពឹងផ្អែកលើការជំរុញប្រជាពលរដ្ឋ។

ការទទួលខុសត្រូវសង្គមដែលប្រកបដោយប្រសិទ្ធភាព គឺត្រូវការចំនុច ឬ សម្ភបួនសំខាន់ៗ ដែនាំអោយការប្រើប្រាស់ពតិមានយ៉ាងមានប្រសិទ្ធភាព ការរៀបចំចាត់ចែងអង្គការសង្គមស៊ីវិល ឬ ក្រុមប្រជាពលរដ្ឋពោរពេញដោយសតម្កភាព(កេណ្ឌការគាំទ្រជាសារណៈ ការតស៊ូមតិ និងការចចាដើម្បីធ្វើការផ្លាស់ប្តូរ)បរិស្ថានមួយដែលមានលក្ខណ:ងាយស្រួលអាចធ្វើទៅបាន (ក្នុងនោះមាន គោលនយោបាយ រនចាសម្ពន្ធ័ ការគាំទ្ររដ្ឋាភិបាល និតិវិធី និងគោលការណ៍)និងភាពខ្ទខ្មានៃវប្បធម៌ (ឧទាហរណ៍ វាត្រូវតែជាបរិបទមួយជាក់លាក់ មានការឆ្លើយតប និងមានបំលាស់ប្តូ)។

ប្រជាណពលរដ្ឋ និងរដ្ឋាភិបាលដើរទួយ៉ាងសំខាន់ក្នុងការទទួលខុសត្រូវសង្គម។ រដ្ឋាភិបាលមានកាតព្វកិច្ចក្នុងការសម្របសម្រួល ក្នុងការទទួលបានពតិមានទាំងអស់ ដោយប្រជាពលរដ្ឋត្រូវតែការពារសិទ្ធិរបស់គាត់

ដើម្បីចូលរួមក្នុងកិច្ចការគ្រប់គ្រង។ មានន័យថាប្រជាពលរដ្ឋត្រូវតែ រៀបចំខ្លួនគាត់ក្នុងការជម្រុញការចូលរួមប្រភេទនេះ។

ការទទួលខុសត្រូវសង្គម កើតឡើងទាំងស្រុងនៅក្នុងវដ្តនៃអភិបាលកិច្ចដោយប្រជាធិបតេយ្យ។ ក្នុងន័យនេះ ភាពជាប្រជាពលរដ្ឋ មិនគួរមានវត្តមានតែនៅក្នុងកំឡុងពេលនៃការបោះឆ្នោតនោះទេ។ វិធីសាស្ត្រនៃការទទួលខុសត្រូវសង្គម ត្រូវការអោយប្រជាពលរដ្ឋមានាការប្រុប្រយត្ន័ និងសង្កេតយ៉ាងខ្ជាប់ខ្ជួនជានិច្ច ទៅលើការអនុវត្តរបស់អ្នកដឹកនាំដែលបានជាប់ឆ្នោត អ្នកផ្តល់សេវា និងកាិយាធិបតេយ្យ។

ការទទួលខុសត្រូវសង្គម គ្របដណ្តប់ លំដាប់ដ៏ធំយ៉ាងសំខាន់ នៃសកម្មនានា ដែលប្រជាពលរដ្ឋអាចអនុវត្តន៏បានយ៉ាងមានសក្តានុពល ដើម្បីត្រួតត្រាមន្ត្រីរដ្ឋាភិបាល និងការិយាធិបតេយ្យដែលមានការទទួលខុសត្រូវ។ សកម្មភាពទាំងអស់នេះប្រហែលជាអនុវត្តន៏ជាទូលំទូលាយមួយ គ្រប់លំដាប់អ្នកចូលរួម។ (ឧទាហរណ៏ប្រជាពលរដ្ឋម្នាក់ៗ តំណាងសហគមន៏នានា CSOs បណ្តាញពត៌មាន) លេចឡើងតាមឋានៈខុសៗគ្នា (ឧទាហរណ៏ពីមូលដ្ឋាន រហូតដល់ថ្នាក់ជាតិ)បញ្ជោក់នូវបញ្ហាខុសៗគ្នាជាច្រើន (ឧទាហរណ៏ គោលនយោបាយជាសាធារណៈលក្ខណនយោបាយ ការចំណាយជាសារធារណៈ ការផ្តល់សេវា ) និងប្រើយុទ្ធសាស្ត្រខុសៗគ្នា (ឧទាហរណ៏ការស្រាវជ្រាវ ការត្រួតពិនិត្យ ការធ្វើផែនការដោយមានការចូលរួម ការអប់រំប្រជាពលរដ្ឋ ប្រពន្ធ័គ្របដណ្តប់ពត៌មាន ការកសាងសហជីព)។

វិធីសាស្ត្រក្នុងការទទួលខុសត្រូវសង្គម បានសន្មត់ថាៈ ទីមួយ រដ្ឋាភិបាលត្រូវបើកទ្វារស្វាគមន៏ការចូលរួមរបស់ប្រជាជន និងទីពីរ ប្រជាពលរដ្ឋត្រូវមានឆន្ទៈក្នុងកាជំរុញរដ្ឋាភិបាល។ ថាមពលនៃការសាមគ្គីគ្នា គឺនាំមកនូវភាពជាដៃគូយាំងសំខាន់រវាងប្រជាជន-រដ្ឋាភិបាល ដែលក្រុមប្រជាពលរដ្ឋ និងអង្គការមិនមែន រដ្ឋាភិបាល ត្រូវមានឆន្ទៈ ក្នុងការពង្រីកលំដាប់នៃសកម្មភាព ដើម្បីជំរុញ ឬ ធ្វើការរួមគ្នាជាមួយរដ្ឋាភិបាល ដើម្បីធានាថា រដ្ឋាភិបាលបាននិងកំពុងបំពេញភារកិច្ច ក្នុងការផ្តល់សេវា ទ្រទ្រង់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងការពារសិទ្ធិប្រជាជន។ វិមជ្ឈការគឺជាវិធីមួយ ដើម្បីជួយក្រុមប្រជាពលរដ្ឋក្នុងការធ្វើអោយរដ្ឋាភិបាលរបស់គាត់មានការទទួលខុសត្រូវ។

## ៣. វិមជ្ឈការ

វិមជ្ឈការគឺជាទង្វើមួយ ដែលជាស្ទូលរបស់រដ្ឋាភិបាល *ការផ្ទេរអំណាច និងការគ្រប់គ្រងជាផ្លូវការ* (ធ្វើផែនការ ធ្វើការសំរេចចិត្ត ឬ គ្រប់គ្រងវិស័យសាធារណៈ) ដើម្បីធ្វើអោយ បណ្តារអ្នកអនុវត្តន៍ ឬ ស្ថាប័ននានា ដែលមានកំរិតទាបបំផុតលើផ្នែក រដ្ឋបាល-នយោបាយ និង ឋានានុក្រមនៃការគ្រប់គ្រង។ ដូច្នេះហើយ វិមជ្ឈការ អាចជាកន្លែង សំរាប់ប្រជាពលរដ្ឋក្នុងការអនុវត្តការទទួលខុសត្រូវសង្គម ដើម្បីទាមទារ អភិបាលកិច្ចល្អពីមន្ត្រីរដ្ឋាភិបាលតាមមូលដ្ឋានរបស់គាត់ផ្ទាល់។

**វិមជ្ឈការគឺជា ......**

គឺជាកំនៃទំរង់ ឬ ការរៀបចំ ឡើងវិញរបស់ អង្គាធរ ដើម្បីមានប្រពន្ធ័ទទួលខុសត្រូវរួម មួយ រវាងស្ថាបន័គ្រប់គ្រង....ដូច្នេះធ្វើអោយប្រសើឡើង នូវគុណភាព និងប្រសិទ្ធ-ភាពរួម សំរាប់ប្រពន្ធ័ គ្រប់គ្រង ក្នុងខណៈពង្រីកកាគ្រប់គ្រង និងសមត្ថភាព អនុថ្នាក់ជាតិ *(UNDP)*. ផ្ទេរការការគ្រប់គ្រង និងការទទួលខុសត្រូវ សំរាប់ វិស័យសាធារណៈ ចាប់ពីរដ្ឋាភិបាលថ្នាក់កណ្តាល រហូតដល់ ថ្នាក់មធ្យម និងថ្នាក់មូលដ្ឋាន ឬ សឹងតែអង្គភាពរដ្ឋាភិបាលឯករាជ្យ និងវិស័យឯកជនផងដែរ *(World Bank)*.។

វិមជ្ឈការមានទំរង់ចំបង២ពីរ។ ដែលរួមមាន វិមជ្ឈការដែលក្នុងនោះមានការធ្វើសេចក្តីសំរេចចិត្ត និងការគ្រប់គ្រង ការទទួលខុសត្រូវ ដែលបានចាត់ចែង ដើម្បីភ្ជាក់ងាររដ្ឋាភិបាលកណ្តាល និងការផ្ទេរ ក្នុងនោះមានទាំង សេវាកម្ម និងតួនាទី ដែលបែងចែកចំពោះអ្នកជាប់ឆ្នោតជាមួយនិងកំរិតស្វ័យភាពតាមមូលដ្ឋានមួយចំនួន។

វិមជ្ឈការ ជាមុខយ៉ាងសំខាន់បំផុតក្នុងការផ្តល់សេវាកម្ម នៃរដ្ឋាភិបាលថ្នាក់ជាតិ រហូតដល់ថ្នាក់តំបន់។ មុខងាររដ្ឋបាល និងការគ្រប់គ្រង ក៏ត្រូវបានរៀបចំឡើងផងដែរចំពោះ មន្ត្រីតាមមូលដ្ឋាន។ តាមរយៈវិមជ្ឈការ ប្រជាជនមិនត្រូវព្យាករណ៍ទុកថា តើមន្ត្រីសាធារណៈណាមួយបរាជ័យ ឬ ជោគជ័យនោះទេ ក្នុងបំពេញកតព្វកិច្ចមួយអាណត្តិ ពួកគាត់ងាយស្រួលឃើញជាង ចាប់តាំងពីកាតព្វកិច្ចធ្លាក់ មកលើដៃមន្ត្រីតាមមូលដ្ឋានរបស់គាត់។

វាក៏ងាយស្រួលជាងក្នុងការទាមទារនូវតម្លាភាព នៅពេលមិនមានទាមទារ ពីព្រោះ ឥឡូវនេះ រដ្ឋាភិបាលដែលកើតចេញពីវិមជ្ឈការ មានភាពជិតស្និតជាមួយប្រជាជន។ នេះជាហេតុផលដែល វិមជ្ឈការត្រូវបានលើកឡើងជាញយ១។ វាបានធ្វើអោយរដ្ឋាបាលមានភាពគៀកកិតនិងប្រជាពលរដ្ឋ ព្រមទាំងផ្តល់ឱកាសក្នុងការចូលរួមធ្វើសេចក្តីសំរេចចិត្តទៀតផង។

ដូច្នេះហើយ ការសំរេចចិត្តដោយមានការចូលរួមត្រូវបានបើកចំហរ តាមរយៈវិមជ្ឈការ ដែលត្រូវតែពង្រីកអោយកាន់តែទូលំទូលាយ និងមានការសង្កត់បញ្ជាក់ច្បាស់លាស់។ " វិមជ្ឈការ មិនមែនគ្រាន់តែជាគុណតម្លៃរដ្ឋាបាលប៉ុណ្ណោះទេ តែជាភាពសំខាន់របស់ប្រជាពលរដ្ឋ ចាប់តាំងពីវាបានពង្រីកនូវឱកាស សំរាប់ប្រជា

ពលរដ្ឋ ដើម្បីធ្វើការចាប់អារម្មណ៍លើកិច្ចការសាធារណៈ លើសពីនេះទៅទៀត វិមជ្ឈការបានផ្តល់ឱកាសថែមទៀត ចំពោះការចូលរួមដោយសេរី និងឱកាសដល់ប្រជាជនក្នុងការជួយធ្វើអោយ ប្រាកដថាភាពរីកចំរើន និងការជឿនលឿនអាចសំរេចទៅបានលើគ្រប់វិស័យ ។ វាជាបច្ច័យដ៏ល្អក្នុងការអភិវឌ្ឍមនុស្សជាត់ប្រកបដោយនិរន្តភាព ។

នេះហើយជាហេតុផល បានជាប្រទេសនិមួយៗសំដៅទៅរកវិមជ្ឈការ ជាបឋមដើម្បីទ្រទ្រង់ ការចាត់ចែងធនធាន និងផ្គត់ផ្គង់សេវា ។ បទពិសោធន៏កន្លងមករបស់បណ្តារប្រទេសនានា បានបង្ហាញថាវាបានធ្វើអោយរដ្ឋាភិបាលពោពេញដោយការទទួលខុសត្រូវ ប្រជាពលរដ្ឋមានការចូលរួមកាន់ច្រើន និងជម្រុញដល់ភគ្គីទាំងពីរអោយចូលរួមអនុវត្តន៍អភិបាលកិច្ចល្អ ។

យ៉ាងណាមិញ តាមរយៈអក្សរសាស្រ្ត និងបទពិសោធន៏ជាច្រើនដែលទាក់ទងទៅនិងវិមជ្ឈការ បានបង្ហាញផងដែរថា "វានឹងមិនសុទ្ធតែធ្វើអោយសំរេចបាននូវគោលដៅ នៃការធ្វើអោយរដ្ឋាភិបាលមូលដ្ឋានមានការ និងឆ្លើយតប និងទទួលខុសត្រូវ នោះទេ " ជារឿយៗវាធ្វើអោយងាយក្នុងការចាប់បានដែលមានលក្ខណៈ សម្រិតសម្រាំងត្រង់ថាៈ ការធ្វើសេចក្តីសំរេចចិត្តជាសាធារណៈ ជាញឹកញាប់ធ្វើការឆ្លុះបញ្ចាំងលើឥទ្ធិពលដែលមិនមានភាពស្មើគ្នា ដោយក្រុមដែលមានទំនាក់ទំនងល្អ ។ នៅបណ្តារប្រទេសជាច្រើន វិមជ្ឈការបានផ្តល់ឱកាសក្នុងការជួញដូរជាផ្លូវការ ដើម្បីលើកស្ទួយសកម្មភាពពាណិជកម្មរបស់គេដោយខ្លួនឯង" ។

ដូច្នេះហើយ វាមានសារៈសំខាន់ត្រង់ថា ទំហំរបស់ប្រជាពលរដ្ឋក្នុងវិស័យវិមជ្ឈការ ត្រូវបានពង្រីកយ៉ាងទូលំទូលាយ និងវិធីមួយក្នុងការធ្វើដូច្នេះ គឺតាមរយៈការប្រើនូវការទទួលខុសត្រូវសង្គម និងក៏រិតធំធេងនៃវិធីសាស្រ្ត ធ្វើរកអោយឃើញថា អភិបាលកិច្ចល្អកើមាននៅថ្នាក់មូលដ្ឋានពិតប្រាកដ ។

## ៤. តួនាទីរបស់ការទទួលខុសត្រូវសង្គម ក្នុងវិស័យវិមជ្ឈការ

ប្រសិទ្ធភាពនៃការផ្តល់សេវាកម្ម នៅថ្នាក់មូលដ្ឋានគឺមានការលើកំពស់យ៉ាងខ្លាំងខ្លា ហើយអាចមាននិរន្តភាពទៅបាន ប្រសិនបើលក្ខណ្ឌពិតប្រាកដសមស្របទៅនឹងប្រពន្ធ័វិមជ្ឈការ នៃការគ្រប់គ្រង ។ លក្ខណ្ឌទាំងនេះរួមមាន លំដាប់នៃប៉ារ៉ាម៉ែត្រ រួមបញ្ចូលទាំងរចនាសម្ពន្ធ័របស់ស្ថាប័ន ធនធាន ជំនាញ និងសមត្ថភាព ទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដាន ការចូលរួម ភាពជាដៃគូរ ដែលមានទាំងភាពជាអ្នកដឹកនាំតាមមូលដ្ឋាន និងផ្នែកផ្សេងៗ ។ ចាប់តាំងពីវាបានបង្ហាញថា ទាំងវិមជ្ឈការ អភិបាលកិច្ចល្អ គឺប្រហែលជាអវត្តមានជាក់ស្តែងមែន ។ សង្គមត្រូវតែរកវិធីសាស្រ្តដើម្បី ធ្វើអោយប្រាកដថា សេវាកម្ម និងការផ្តល់សិទ្ធិអំណាចដោយពួកគេគឺមានការព្រមព្រៀងគ្នា ។

ការទទួលខុសត្រូវសង្គម និងក៏រិតនៃវិធីសាស្រ្តដ៏ធំធេងរបស់វា អាចធ្វើជាឧបករណ៍សំរាប់ប្រជាពលរដ្ឋ ដែលប្រើដើម្បី រកអោយឃើញនូវអភិបាលកិច្ចល្អ នៅថ្នាក់មូលដ្ឋាន និងមានឥទ្ធិពលនៅក្នុងរដ្ឋាភិបាលថ្នាក់ជាតិ ។

ខាងក្រោមនេះជាវិធីសាស្រ្តមួយចំនួនរបស់ការទទួលខុសត្រូវសង្គម ភាប់ជាមួយឧទាហរណ៍ នៃការអនុវត្ត វិធីសាស្រ្តទាំងនេះ ដោយសហគមន៍ និងក្រុមប្រជាពលរដ្ឋជាច្រើន ខុសៗគ្នានៅក្នុងពិភពលោក ។

ក. ការធ្វើផែនការដោយមានការចូលរួម និងការតាត់តែងគោលនយោបាយៈ និយាយដោយសាមញ្ញ វិធីសាស្រ្តនេះ អនុញ្ញាតិអោយប្រជាពលរដ្ឋ ដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្តរបស់ រដ្ឋាភិបាល ។

ខ. ការវិភាគថវិកាដោយមានការចូលរួមៈ ប្រជាពលរដ្ឋ តាមរយៈវិធីសាស្រ្តនេះ នឹងត្រូវពិនិត្យ មើលផលប៉ះពាល់ និងទំនាក់ទំនង នៃការចាត់ចែងថវិការបស់រដ្ឋាភិបាល និងធ្វើការផ្សព្វផ្សាយ បញ្ហាដែល ទាក់ទងនិងថវិកា ។

គ. ការតាមដានការចំណាយ ដោយមានការចូលរួមៈ វិធីសាស្រ្តនេះ ធ្វើអោយប្រជាពលរដ្ឋ ត្រួតពិនិត្យ និងតាមដាន ការទុកដាក់ប្រាក់ពន្ធដាររបស់រដ្ឋាភិបាល ។

ឃ. ការអង្កេតរបស់ប្រជាពលរដ្ឋ/បណ្ណ័របាយការណ៏ប្រជាជនៈ វិធីសាស្រ្តនេះមានសារសំខាន់ក្នុងការ ប្រមែប្រមូលពតិមានត្រឡប់របស់ប្រជាពលរដ្ឋ ដែលមានលក្ខណៈរួមផ្តុំ និងបង្ហាញទៅដល់សាធារណៈទូទៅ ដូចជា បណ្ណ័របាយការណ៏ នៃការអនុវត្តចាផ្លូវការទៅតាមលំដាប់នៃបញ្ហាខុសៗគ្នាជាដើម ។

ង. ធម្មនិញ្ញប្រជាជនៈ នេះជាការថ្លែងយ៉ាងជាក់ស្តែងមួយ នូវអ្វីដែលភ្នាក់ងារសាធារណៈ បានរៀបចំរួច ជាស្រេច ដើម្បីផ្តល់សេវា និងសិទ្ធិក្នុងការឆ្លើយឆ្លង ព្រមទាំងផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការបង្ការដែលអាចរកបាន នៅពេលដែលមានជំលោះកើតឡើង ។ វាធ្វើការសង្ខេបនូវ ទួនាទី និងការទទួលខុសត្រូវ របស់អ្នកផ្តល់សេវា ហើយ ប្រជាពលរដ្ឋធ្វើការប៉ាន់ប្រមាណលើការប្រតិបត្តិពីអតីត តាមរយៈបទដ្ឋាននានារៀបចំដោយធម្មនុញ្ញ ។

ច. បណ្ណ័បន្ទុះរបស់សហគមន៏ៈ វិធីសាស្រ្តនេះប្រើដើម្បី ឈានទៅរកការចែកចាយសេវា ដោយមានការចូល រួមនៅលំដាប់សហគមន៏ ។

ឆ. យន្តការនៃការតវ៉ាៈ នេះជាឧបករណ៏សំរាប់ដំណើការក្នុងការជំរុញអ្នកពាក់ពន្ធ័ទូទៅ និងការសន្ទនា ដែលអាចជួយក្នុងការការពារជំលោះ ការគ្រប់គ្រងជំលោះ និងការដោះស្រាយជំលោះ ។ វាផ្តល់នូវបណ្តាញឆ្លាស់គ្នា ដែលប្រជាពលរដ្ឋអាចទទួលស្គាល់ ដើម្បីដោះស្រាយការព្រួយបារម្ភដោយស្របច្បាប់ ជម្រុញដំណើរការដើម្បី រកអោយឃើញនូវដំណោះស្រាយនានា ដែលអាចទទួលយកបាន និងចែករំលែកភាពជាម្ចាស់នៃដំណើការនោះដល់ រដ្ឋាភិបាល ។

ការទទួលខុសត្រូវសង្គម ដែលបានបង្ហាញតាមរយៈបទពិសោធន៍របស់ប្រជាពលរដ្ឋ ដែលជាអ្នកអនុវត្តន៏វិធីសាស្ត្រនានារបស់វា បានផ្តល់សារៈប្រយោជន៏យ៉ាំងធំធេងដោយឥតសង្ស័យ និងមានការផ្លាស់ប្តូរជាវេជ្ជមានដល់ដំណើការអនុវត្តន៏ការងាររបស់រដ្ឋាភិបាល។ វិធីសាស្ត្រទាំងនេះ ត្រូវបានរៀបចំ និងអនុវត្តន៏ជាសំខាន់ដោយប្រជាពលរដ្ឋ និងក្រុមប្រជាជន។ ការទទួលខុសត្រូវសង្គម និងជាវិធីសាស្ត្រអមដែលអាចសម្របសម្រួលផ្លូវសំរាប់អភិបាលកិច្ចល្អ ក្នុងជួររដ្ឋាភិបាលក្នុងតំបន់ និងមានឥទ្ធពលដល់រដ្ឋាភិបាលថ្នាក់ជាតិ។

## ៥. អភិបាលកិច្ចល្អ ការទទួលខុសត្រូវសង្គម ក្នុងវិស័យវិមជ្ឈការ

ឬសគល់នៃអភិបាលកិច្ចល្អ វិមជ្ឈការ និងការទទួលខុសត្រូវសង្គម កើតចេញមកពីគោលបំណងនៃកាអភិវឌ្ឍមនុស្ស និងទិសដៅចំបងៗ លើកស្ទួយការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកដោយប្រសិទ្ធភាព និងមាននិរន្តភាព តាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រង។

អភិបាលកិច្ចល្អរបស់រដ្ឋាភិបាល គឺយើងត្រូវតែសង្ឃឹមថាអ្វីៗទាំងអស់មានភាពប្រសើឡើង។ យ៉ាងណាមិញ វាជាគុណតម្លៃដែលមិនមែនកើតឡើងតែក្នុងពេលបច្ចុប្បន្ន ជារឿយៗវាត្រូវតែមានការទាមទារជាផ្លូវការ។ ការទទួលខុសត្រូវសង្គម គឺជាវិធីសាស្ត្រមួយសំរាប់ប្រជាពលរដ្ឋក្នុងការទាមទារអភិបាលកិច្ចល្អ រួមទាំងការប្រតិបត្តិនូវតួនាទីសំខាន់ៗ ក្នុងការអនុវ្តការងាររបស់រដ្ឋាភិបាលផងដែរ។

អភិបាកិច្ចដែលមានភាពល្អប្រសើរ នឹងមិនមែនគ្រាន់តែពង្រឹងរដ្ឋាភិបាលកណ្តាល និងមុលដ្ឋានប៉ុណ្ណោះទេ តែត្រូវមានការចូលរួមពីសំណាក់ស្ថាន័នផ្សេងៗ រួមមាន អង្គការសង្គមស៊ីវិល និងស្ថប័នឯកជន ដោយធ្វើជាដៃគូរជាមួយរដ្ឋាភិបាល គ្រប់ជាន់ថ្នាក់ទាំងអស់ តាមរយៈករទទួលខុសត្រូវសង្គម។ ប្រជាពលរដ្ឋ និងរដ្ឋាភិបាលដើរតួយ៉ាងសំខាន់បំផុតក្នុងការទទួលខុសត្រូវសង្គម។ រដ្ឋាភិបាលមានកាតព្វកិច្ច ក្នុងការសម្របសម្រួល ដើម្បីអោយទទួលបានពតិមានទាំងអស់ ដោយប្រជាពលរដ្ឋត្រូវតែការពារសិទ្ធិរបស់គាត់ ដើម្បីចូលរួមក្នុងកិច្ចការគ្រប់គ្រង។ មានន័យថាប្រជាពលរដ្ឋត្រូវតែ រៀបចំខ្លួនគាត់ក្នុងការជម្រុញការចូលរួមប្រភេទនេះ។

ចំពោះយន្តការនៃការទទួលខុសត្រូវសង្គម ដើម្បីធ្វើអោយមានប្រសិទ្ធភាពរយៈពេលវែង វាត្រូវតែមានមូលដ្ឋាន និងផ្សារភ្ជាប់ទៅនិង រចនាសម្ពន្ធ័អភិបាលកិច្ច និងប្រពន្ធ័នៃការផ្គត់ផ្គង់សេវាកម្ម ដែលមានស្រាប់។

ប្រសិទ្ធភាពនៃការផ្តល់សេវាកម្ម នៅថ្នាក់មូលដ្ឋានគឺមានការលើកំពស់យ៉ាងខ្លាំងខ្លា ហើយអាចមាននិរន្តភាពទៅបាន ប្រសិនបើលក្ខណ្ឌពិតប្រាកដសមស្របទៅនឹងប្រពន្ធ័វិមជ្ឈការ នៃការគ្រប់គ្រង។ លក្ខណ្ឌទាំងនេះរួមមាន លំដាប់នៃប៉ារ៉ាម៉ែត្រ រួមបញ្ចូលទាំងរចនាសម្ពន្ធ័របស់ស្ថាប័ន ធនធាន ជំនាញ និងសមត្ថភាព ទាំងនៅថ្នាក់កណ្តាល និងថ្នាក់មូលដាន ការចូលរួម ភាពជាដៃគូរ ដែលមានទាំងភាពជាអ្នកដឹកនាំតាមមូលដ្ឋាន និងផ្នែក

ផ្សេងៗ។ តាមរយៈវិមជ្ឈការប្រកដោយប្រជាធិបតេយ្យ ការជម្រុញប្រជាពលរដ្ឋ ដើម្បីការទទួលខុសត្រូវសង្គម អាចត្រូវបានធ្វើការផ្តោតអារម្មណ៍ និងផលប៉ះពាល់របស់វាងាយស្រួលដឹង។

ការចូលរួម




ការទទួលត្រូវសង្គម តម្លាភាព

## References

2007. Governance. In the Data Report. Available at http://www.thedatareport.org

A. de Tocqueville. 1835. Democracy in America. Reprinted 2003. Penguin Classics.
Wong, Susan and Guggenheim, Scott. No date. Community-Driven Development: Decentralization's Accountability Challenge.

Arroyo, Dennis and Sirker, Karen. 2005. Stocktaking of Social Accountability Initiatives in the Asia and the Pacific Region. World Bank Institute.
Arroyo, Dennis. December 2004. *Summary Paper on the Stocktaking of Social Accountability Initiatives in Asia and the Pacific*. World Bank Institute Community Empowerment and Social Inclusion Learning Program.

Malena, Carmen with Forster, Reiner, Singh, Janmejay. 2004. Social Accountability: An Introduction to the Concept and Emerging Practice. *In Social Development Papers*. The World Bank.

Malena, Carmen with Forster, Reiner, Singh, Janmejay. 2004. Social Accountability: An Introduction to the Concept and Emerging Practice. *In Social Development Papers*. The World Bank.

Misra, Vivrek. 2005. Framework for Government Accountability. CGG

Robertson Work, "The Role of Participation and Partnership in Decentralised Governance:  A Brief Synthesis of Policy Lessons and Recommendations of Nine Country Case Studies on Service Delivery for the Poor, (UNDP New York).

The Australian Government's Overseas Aid Program (AusAID). August 2000. *Good Governance: Guiding Principles for Implementation*. Australian Agency for International Development (AusAID), Canberra.

The Independent Commission on Good Governance in Public Services. 2004. *The Good Governance Standard for Public Services*. OPM and CIPFA.

The World Bank. No year. *From Shouting to Counting: A New Frontier in Social Development.* World Bank, Washington D.C.

Tucker, Stevens. May 22, 2007. Decentralization – Core Concepts and Challenges. Paper presnbeted at the Workshop on The Theory and Practice of Decentralisation and Deconcentration (Social Sectors), Phnom Penh.

The International Bank for Reconstruction and Development/The World Bank. 2005.
Social Accountability in the Public Sector. Washington DC.

Wong, Susan and Guggenheim, Scott. No date. Community-Driven Development: Decentralization's Accountability Challenge.